អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

*ភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២*

# សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ

នាថ្ងៃម្សិលមិញនេះ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ Laurent Kasper Ansermet បានផ្ញើនូវសេចក្តីប្រកាសព័ត៌មានមួយយ៉ាងប្រញាប់ប្រញាល់បំផុត នៅចុងម៉ោងធ្វើការរបស់ អ.វ.ត.ក ដែលសហចៅក្រមស៊ើបអង្កេតជាតិយល់ឃើញថា ៖

១. ការលួចចេញនូវសេចក្តីប្រកាសព័ត៌មាននៅពីក្រោយខ្នងសហចៅក្រមស៊ើបអង្កេតជាតិម្តងហើយម្តងទៀតគឺជាការបង្ហាញនូវចេតនាមិនល្អរបស់លោក Laurent Kasper-Ansermet ។

២. ខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់លោក Kasper-Ansermet បង្ហាញយ៉ាងច្បាស់ក្រឡែតនូវចេតនាបំភ័ន្តមតិសាធារណៈ ជាពិសេសចំណុច ដែលថា *"សហចៅក្រមស៊ើបអង្កេតជាតិជំទាស់ទៅនឹងសំណើបំពេញកិច្ចស៊ើបសួរដែលបានស្នើឡើងដោយលោក (*Kasper-Ansermet*)"* ។ សហចៅក្រមស៊ើបអង្កេតជាតិសូមបញ្ជាក់ជាថ្មីថា សហចៅក្រមជាតិមិនដែលបានពិភាក្សាលើបញ្ហាកិច្ចនីតិវិធីណាមួយជាមួយលោកចៅក្រម Laurent Kasper-Ansermet ឡើយ ហើយរឹតតែមិនដែលធ្លាប់បានខ្វែងយោបល់អំពីចំណាត់ការនីតិវិធីណាមួយជាមួយគាត់ដែរ។ នាពេលកន្លងមក សហចៅក្រមស៊ើបអង្កេតជាតិតែងតែគោរពជានិច្ចនូវជំហរឯករាជ្យរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហើយជាពិសេស កិច្ចព្រមព្រៀង ច្បាប់អ.វ.ត.ក និងវិធានផ្ទៃក្នុង មានចែងយ៉ាងច្បាស់អំពីយន្តការក្នុងការដោះស្រាយនូវការខ្វែងយោបល់គ្នារបស់សហចៅក្រមទាំងពីរដើម្បីធានាបាននូវដំណោះស្រាយបញ្ហាមួយស្របតាមគោលការណ៍ជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។ ជាក់ស្តែង យន្តការនេះត្រូវបានអនុវត្ត និងគោរពតាម នៅក្នុងការដោះស្រាយការខ្វែងយោបល់គ្នាដែលធ្លាប់មានកន្លងមករវាងសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel Lemonde និងសហចៅក្រម Siegfried Blunk នៅក្នុងក្របខ័ណ្ឌនៃសំណុំរឿងស៊ើបសួរដែលមាននៅ អ.វ.ត.ក។

៣. ការលើកឡើងអំពីមាត្រានៃកិច្ចព្រមព្រៀង និងមាត្រានៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក គ្រាន់តែជាការបំផ្លើសរបស់ចៅក្រម Laurent Kasper-Ansermet ប៉ុណ្ណោះ ដោយហេតុថា មិនមានមាត្រាណាមួយនៅក្នុងចំណោមមាត្រាទាំងនោះ អនុញ្ញាតឲ្យលោក Kasper-Ansermet មានសិទ្ធិធ្វើចំណាត់ការណាមួយក្នុងនាមជាសហចៅក្រមស៊ើបអង្កេតបម្រុងនៅក្នុងករណីកន្លែងសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅទំនេរឡើយ ផ្ទុយទៅវិញមាត្រា ៥.៦ នៃកិច្ចព្រមព្រៀងតម្រូវឲ្យមានការតែងតាំងសហចៅក្រមស៊ើបអង្កេតបម្រុងជាសហចៅក្រមពេញសិទ្ធិសិន។ នេះគឺស្របតាមការអនុវត្តកន្លងមកចំពោះករណីសហចៅក្រមស៊ើបអង្កេតអន្តរជាតិមុនៗ។

៤. សកម្មភាពរបស់លោក Laurent Kasper-Ansermet បង្ហាញអំពីកង្វះខាតផ្នែកការយល់ដឹង ឬការគោរពចំពោះវិធានផ្ទៃក្នុង និងគោលការណ៍ច្បាប់ ដែលអនុវត្តនៅអ.វ.ត.ក. ដែលនាំឲ្យសហចៅក្រមជាតិឆ្ងល់ថា ភាពចចេសរឹងរូស និងការបង្កឲ្យបាត់បង់នូវការអនុវត្តច្បាប់ និងវិធានផ្ទៃក្នុងនៅ អ.វ.ត.ក របស់លោក

ចៅក្រមបម្រុងរូបនេះធ្វើឡើងដើម្បីអ្វី? ជាក់ស្តែង ដោយមិនគិតដល់កង្វះលក្ខណៈសម្បត្តិតាមផ្លូវច្បាប់របស់លោក Kasper-Ansermet ការចេញនូវសេចក្តីប្រកាសព័ត៌មានទាក់ទងទៅនឹងចំណាត់ការនីតិវិធីដែលខ្លួនបានធ្វើដោយយោងទៅវិធាន ២១.១ (គ) គឺមិនត្រឹមត្រូវឡើយ ខណៈវិធាននេះមិនមែនជាវិធានដែលត្រូវអនុវត្តដើម្បីចេញនូវសេចក្តីប្រកាសព័ត៌មានទាក់ទងនឹងសំណុំរឿងស៊ើបសួរឡើយ។

៥. ការចេញនូវសេចក្តីប្រកាសព័ត៌មានរបស់លោក Kasper-Ansermet នេះកាន់តែនាំឲ្យសហចៅក្រមស៊ើបអង្កេតជាតិមានមន្ទិលកាន់តែខ្លាំងឡើងអំពីវិជ្ជាជីវៈរបស់លោកចៅក្រម Kasper-Ansermet ថាតើគាត់មានវិជ្ជាជីវៈជាចៅក្រម ឬ ជាអ្នកផ្សព្វផ្សាយសារព័ត៌មាន?

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh